# សុន្ទរកថា

# ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
# ក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

- ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប
- ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត
- លោក លោកស្រី ប្រធានក្រុមប្រឹក្សា អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- លោក លោកស្រី តំណាងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ និង
- អង្គពិធីទាំងមូល ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយ ដោយបានចូលរួមក្នុងពិធីផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តអនុក្រឹត្យស្ដីពី **ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ** ដ៏អធិកអធមនា ដែលមានអ្នកចូលរួមពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ជាពិសេសប្រធានក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេស ដែលសុទ្ធសឹងជាប្រតិបត្តិករផ្ទាល់លើមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាល ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចាប់ពីឆ្នាំ២០២៤ តទៅ។



TPPL

ការផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពី **ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ** នាថ្ងៃនេះ គឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ ដែលបង្ហាញពីវឌ្ឍនភាពថ្មីមួយទៀត ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់វិស័យអប់រំ ព្រមទាំងបានបង្ហាញអំពីឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់អាទិភាព និងការគាំទ្រដល់វិស័យអប់រំ យុវជន និងកីឡា។

ក្នុងនាមថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរដ៏ស្មោះចំពោះរាល់កិច្ចសហការ ការចូលរួម និងការគាំទ្រពីគ្រប់ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ ក្នុងការជំរុញនិងលើកកម្ពស់ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការការងារអប់រំឱ្យកាន់តែល្អប្រសើរ ជាពិសេស **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធាន គ.ជ.អ.ប. ដែលបានផ្តល់ការគាំទ្រ និងរៀបចំពិធីផ្សព្វផ្សាយដ៏មានសារៈសំខាន់នេះឡើង។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ គ.ជ.អ.ប ដែលនាពេលកន្លងមក ក្រោមការដឹកនាំរបស់ **សម្តេចក្រឡាហោម ស ខេង** តែងតែផ្តោតការយកចិត្តទុកដាក់ក្នុងការណែនាំ តម្រង់ទិស ជំរុញ និងគាំទ្រដល់ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្កើនគុណភាពនៃសេវាអប់រំជូនដល់ប្រជាជនគ្រប់រូប។

ខ្ញុំសូមគូសបញ្ជាក់ជូនអង្គពិធីជ្រាបថា នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា បានកំណត់យក **ការអភិវឌ្ឍធនធានមនុស្សគឺជាអាទិភាពទី១** ហើយ **ការពង្រឹងគុណភាពអប់រំ យុវជន និងកីឡា** ត្រូវបានកំណត់ជាមុំទី ១ នៃបញ្ចកោណទី១។ ក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្មដ៏សំខាន់គឺ ការធានាដល់ការរៀបចំ និងការផ្តល់សេវាអប់រំ យុវជន និងកីឡាជាទូទៅនៅគ្រប់កម្រិតជូនប្រជាជនគ្រប់រូប ប្រកបដោយគុណភាព ប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គម។ ជាមួយគ្នានេះ នៅក្នុងកិច្ចប្រជុំដំបូងគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់អំពី"ការលើកកម្ពស់គុណភាពអប់រំ" ដោយផ្តោតលើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា តាមរយៈការពង្រឹងកិច្ចការសំខាន់ៗ រួមមាន៖

ទី១.ការពង្រឹងអភិបាលកិច្ចសាលារៀន

ទី២.ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

ទី៣.ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យ គុណភាពចំណីអាហារនៅតាមសាលា

ទី៤.ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

ដើម្បីអនុវត្តចក្ខុវិស័យរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បី "លើកកម្ពស់គុណភាពអប់រំ" ខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ ជាពិសេស«កំណែទម្រង់សាលារៀន» ឱ្យកាន់តែមានប្រសិទ្ធភាពជាមុន ដោយផ្តោតលើការប្រែក្លាយសាលារៀន ឱ្យក្លាយទៅជា «សាលារៀនគំរូ» ដែលផ្តោតលើស្តង់ដា ចំនួន ៥ ដូចខាងក្រោម៖

ស្តង់ដាទី១៖ សាលារៀនដំណើរការសម្រេចផលសម្រេចការអប់រំនិងក្នុងការរៀនសូត្ររបស់សិស្ស៖គឺការអនុវត្តស្តង់ដាសាលារៀន ដែលក្នុងនោះមានទាំងស្តង់ដានាយក ក៏ដូចជាមានទាំងការបង្កើត «គណៈកម្មការគ្រប់គ្រងសាលារៀន» ដែលមានការចូលរួមពីសហគមន៍ និងមាតាបិតា ដើម្បីសម្រេចនូវគណនេយ្យភាព ចំពោះមាតាបិតា ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងចំពោះអាជ្ញាធរមូលដ្ឋាន។ សាលារៀន គឺជាទីកន្លែងមួយសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្រ ដែលគោលដៅរបស់យើង គឺលទ្ធផលសិក្សារៀនសូត្ររបស់សិស្ស។

ស្តង់ដាទី២៖ ថ្នាក់រៀនដែលដំណើរការសម្រេចលទ្ធផលការអប់រំ និងក្នុងការរៀនសូត្ររបស់សិស្ស៖ គឺជា ថ្នាក់រៀនដែលមាន «គណៈកម្មការគ្រប់គ្រងថ្នាក់រៀន» ដោយមានការចូលរួមពីមាតាបិតា ដើម្បីជួយគាំទ្រថ្នាក់រៀន និងកែលម្អបរិស្ថានសាលារៀន ក្នុងគោលដៅដើម្បីឱ្យសិស្សស្រឡាញ់សាលារៀន មានឯកសណ្ឋានល្អ ចង់មកសាលា ចេះច្រៀងចម្រៀង ហាត់កីឡា។ ដូចនេះ គឺត្រូវរៀបចំបរិស្ថានសិក្សាឱ្យបានល្អឱ្យក្មេងចង់មកសាលានេះ។



TPPL

ស្តង់ដារទី៣៖ ការចូលរួមរបស់សហគមន៍និងមាតាបិតានៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន។ ប្រសិនបើឪពុកម្តាយមិនជួយគាំទ្រសាលារៀនទេ កំណែទម្រង់មិនបានជោគជ័យទេ។ កំណែទម្រង់សាលារៀនរបស់យើងទទួលបានជោគជ័យ គឺមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ពីសហគមន៍ ពីមាតាបិតានៅក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ហើយនិងការរៀបចំ «ផែនការកែលម្អសាលារៀន»។ តើសាលារៀនយើងមានបញ្ហាអ្វី ត្រូវដោះស្រាយបែបណា? ខ្វះអ្វី? នេះគឺជាចំណុចគន្លឹះដើម្បីគាំទ្រគ្នាទៅវិញទៅមក។

ស្តង់ដារទី៤៖ គឺការប្រតិបត្តិ និងរដ្ឋបាលសាលារៀន៖ ដោយផ្តោតលើរដ្ឋបាលសាលារៀន ការគ្រប់គ្រងគ្រូ ការកែលម្អការរៀន និងបង្រៀន ការដោះស្រាយបញ្ហាខ្វះគ្រូ លើសគ្រូ គ្រូបង្រៀនអត់ទៅតាមមុខវិជ្ជា ការរៀបចំផែនការដំណើរការសាលារៀន ការផ្តល់សម្ភារៈឧបទេស រួមទាំងវិធីសាស្ត្របង្រៀន។ គោលដៅនៃកំណែទម្រង់សាលារៀន គឺចង់ បណ្តុះបំណិនសតវត្សទី២១ ចង់ឱ្យសិស្សមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ សម្រាប់សាលាបឋមសិក្សា វិធីសាស្ត្របង្រៀនត្រូវផ្តោតលើអំណានដំបូង និងគណិតដំបូង ហើយសម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យ គឺផ្តោតលើវិធីសាស្ត្របង្រៀនទំនើប។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

**អង្គពិធីទាំងមូល ជាទីមេត្រី!**

នាពេលកន្លងមក ក្នុងក្របខណ្ឌនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានប្រគល់មុខងារចំនួន ៣ រួមមានការអប់រំកុមារតូច, ការអប់រំបឋមសិក្សា, និងការអប់រំក្រៅប្រព័ន្ធ និងបានធ្វើប្រតិភូកម្មមុខងារចំនួន ៣ រួមមាន ការងាររដ្ឋបាលគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ, ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា ទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ការប្រគល់មុខងារ និងការធ្វើប្រតិភូកម្មមុខងារនេះ ត្រូវអនុវត្តសាកល្បងនៅក្នុងរដ្ឋបាលក្រុង ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង។

ក្នុងអំឡុងពេលនៃការផ្ទេរមុខងារអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ វិបត្តិនៃជំងឺកូវីដ-១៩គឺជាឧបសគ្គដ៏ធំមួយ ដែលបានធ្វើឱ្យរាំងស្ទះដល់ការរៀបចំយន្តការគាំទ្រ, ការរៀបចំសេចក្តីណែនាំបច្ចេកទេស, ការរៀបចំវគ្គបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវនិងពេញ



TPPL

លេញ, និងការចុះផ្តល់អន្តរាគមន៍គាំទ្របច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃឱ្យបានដិតដល់។

ទោះជាយ៉ាងណា ផ្អែកតាមលទ្ធផលនៃការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាដើមឆ្នាំ២០២៣ បានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ **បានទទួលលទ្ធផលល្អ ពុំមានហានិភ័យធ្ងន់ធ្ងរកើតឡើង**។ ការសិក្សាវាយតម្លៃនេះ ក៏បានបង្ហាញឱ្យឃើញថា ការអនុវត្តមុខងារអប់រំនៅតាមរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងមានលទ្ធផលល្អប្រសើរ ដោយសារ**បានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងបានធ្វើសមាហរណកម្ម**ទាំងការិយាល័យអប់រំ យុវជន និងកីឡា ទាំងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ ព្រមទាំងបុគ្គលិកអប់រំ មកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក។ ប្រការនេះបានជំរុញឱ្យរដ្ឋបាលក្រុង ស្រុក មានការទទួលខុសត្រូវក្នុងភាពម្ចាស់ការ, មានយន្តការស្ថាប័ន, និងខ្សែគណនេយ្យភាពច្បាស់លាស់ ក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ។ ទន្ទឹមគ្នានេះ ការសិក្សាវាយតម្លៃខាងលើ ក៏បានបង្ហាញថា បញ្ហាប្រឈមជារួម គឺជាបញ្ហាប្រឈមផ្នែកបច្ចេកទេស ពុំមែនជាបញ្ហាប្រឈមផ្នែកនយោបាយដែលមានភាពសាំញ៉ាំ ស្មុគ្រស្មាញ និងពិបាកដោះស្រាយនោះឡើយ។

ជាថ្មីម្តងទៀត ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមចូលរួមអបអរសាទរចំពោះលទ្ធផលល្អប្រសើរនេះ ហើយខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានខិតខំប្រឹងប្រែងដឹកនាំ គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យនាពេលកន្លងមក ដោយធានារក្សាបាននូវប្រក្រតីភាពនៃការផ្តល់សេវាអប់រំនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា បឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ជាពិសេសការចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩យ៉ាងសកម្ម និងការឆ្លើយតបភ្លាមៗទៅនឹងវិបត្តិ ដោយធានាបាននូវសុវត្ថិភាពសុខភាពរបស់សិស្សានុសិស្សនិងបុគ្គលិកអប់រំ ព្រមទាំងធានាបាននូវនិរន្តរភាពនៃការរៀនសូត្ររបស់សិស្សានុសិស្សផងដែរ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

អង្គពិធីទាំងមូល ជាទីមេត្រី!

លទ្ធផលនៃការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ ត្រូវបានយកមកពិភាក្សាពិគ្រោះយោបល់យ៉ាងល្អិតល្អន់នៅក្នុងកិច្ចប្រជុំរបស់ គ.ជ.អ.ប. ដើម្បីកំណត់វិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈម និងសិក្សាអំពីជម្រើសសម្រាប់ពង្រីកការធ្វើវិមជ្ឈការមុខងារអប់រំ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវអនុក្រឹត្យលេខ២១៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី **ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ** ក្នុងគោលបំណងពង្រីកការធ្វើវិមជ្ឈការមុខងារអប់រំ យុវជន និងកីឡាដូចដែលបានអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង ទៅអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសចាប់ពីខែមករា ឆ្នាំ២០២៤ តទៅ។

ដើម្បីជាមូលដ្ឋាន ក្នុងការអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ ខ្ញុំសូមគូសរំលេចនូវចំណុចសំខាន់ៗ មួយចំនួន ដូចខាងក្រោម៖

១. ការធ្វើវិមជ្ឈការមុខងារអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសនេះ ផ្តោតលើ "**ការប្រគល់មុខងារគ្រប់គ្រង**" ចំនួន ៣ រួមមាន ការអប់រំកុមារតូច, ការអប់រំបឋមសិក្សា, និងការអប់រំក្រៅប្រព័ន្ធ និង "**ការធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាល**" ចំនួន ៣ ដល់គ្រឹះស្ថានមធ្យមសិក្សាចំណោះទូទៅ, ការងារអភិវឌ្ឍយុវជន និងការងារអប់រំកាយនិងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

២. ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់តាមអនុក្រឹត្យនេះ គឺជាធនធានមានភ្ជាប់លក្ខខណ្ឌ។

៣. បុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានលក្ខខណ្ឌការងារ បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ មិនទាបជាងលក្ខខណ្ឌការងារ បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនការផ្ទេរ។ ការផ្លាស់ប្តូរទីកន្លែងបម្រើការងារនិងការផ្ទេរក្របខណ្ឌគ្រូបង្រៀនត្រូវអនុវត្តតាមគោលនយោបាយ



TPPL

គោលការណ៍ លិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលការណ៍ បែបបទ នីតិវិធីពាក់ព័ន្ធជាធរមាន។

៤. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ។

៥. ការតែងតាំង និងការបញ្ចប់មុខតំណែងនាយក នាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម កម្រិតមូលដ្ឋាន និងកម្រិតឧត្តម និងព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

៦. ពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រូបង្រៀន ខ្ញុំស្នើសុំឱ្យថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀនឱ្យស្របទៅតាមគោលនយោបាយ និងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងស្តង់ដាគ្រូបង្រៀន និងជាពិសេសត្រូវចៀសវាងការប្រើប្រាស់គ្រូបង្រៀន និងបុគ្គលិកអប់រំទៅបំពេញការងារផ្សេង ឬផ្ទេរគ្រូបង្រៀនចេញទៅស្ថាប័នផ្សេងដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការបំពេញការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡា សាលារៀន និងប៉ះពាល់ដល់គុណភាពសេវាអប់រំ។ ជាមួយគ្នានេះក៏ត្រូវយកចិត្តទុកដាក់ទៅលើការរៀបចំតែងតាំងប្រធានការិយាល័យអប់រំ យុវជន និងកីឡា និងនាយកគ្រឹះស្ថានសិក្សាសាធារណៈឱ្យបានត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៧. ថវិកាដំណើរការរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ នឹងនៅតែបន្តផ្ទេរត្រង់ទៅឱ្យគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍។ ខ្ញុំសូមគូសបញ្ជាក់ថា ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ថវិកាដំណើរការសាលារៀន គឺជាថវិកាមានភ្ជាប់លក្ខខណ្ឌ ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវប្រើប្រាស់សម្រាប់ការងារអប់រំ ស្របតាមលក្ខខណ្ឌ និងនីតិវិធីជាធរមាន។ បន្ថែមពីលើសនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់ខ្លួន និង



TPPL

ធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីគាំទ្រការងារអប់រំក្នុងក្របខណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួន។

៨. ទោះបីជាការផ្ទេរវិមជ្ឈការមុខងារអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួងអប់រំ យុវជន និងកីឡានៅតែជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាលើវិស័យអប់រំ យុវជន និងកីឡា។ ក្នុងន័យនេះ ក្រុមប្រឹក្សា និងគណៈអភិបាលនៃ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ព្រមទាំងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះប្រជាជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនលើលទ្ធផលនៃការអនុវត្តមុខងារអប់រំ ដែលបានផ្ទេរឱ្យទាំងនោះ ដោយត្រូវធានាឱ្យបានថា ការអនុវត្តមុខងារទាំងនេះត្រូវតែស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ កម្មវិធីសិក្សាជាតិ និយាម និងស្តង់ដានានាដែលបានកំណត់។

៩. ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំសៀវភៅណែនាំស្តីពីគោលការណ៍បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំដែលបានផ្ទេរឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងរៀបចំការបណ្តុះបណ្តាលជូនដល់ថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាចុងឆ្នាំ២០២៣ ឬដើមឆ្នាំ២០២៤នេះ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានសមត្ថភាពក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំទាំងនេះចាប់ពីដើមឆ្នាំ២០២៤ តទៅ។

១០. ក្រសួងអប់រំ យុវជន និងកីឡានឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំយន្តការគាំទ្រឱ្យបានច្បាស់លាស់ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានី ខេត្ត សម្រាប់ផ្តល់អន្តរាគមន៍គាំទ្រ តាមដាន ត្រួតពិនិត្យជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរឱ្យទាំងនេះ។

១១. ដើម្បីធានាឱ្យការអនុវត្តមុខងារក្នុងវិស័យអប់រំនេះបានល្អប្រសើរ ខ្ញុំក៏ស្នើសុំឱ្យរដ្ឋបាលរាជធានី ខេត្ត ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរពាក់ព័ន្ធដទៃទៀត ត្រូវផ្តល់ការគាំទ្រទាំងសមត្ថភាព បច្ចេកទេស និងការគាំទ្រផ្សេងៗទៀត ព្រមទាំង



TPPL

តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងអន្តរាគមន៍ដោះស្រាយបញ្ហាប្រឈមនានាឱ្យបានទាន់ពេលវេលា ដើម្បីជួយដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនេះ។

ខ្ញុំមានជំនឿជាក់យ៉ាងមុតមាំថា រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តនូវមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាលទាំងនេះ ប្រកបដោយជោគជ័យ ក្រោមស្មារតីទទួលខុសត្រូវខ្ពស់។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសផ្សព្វផ្សាយ និងការដាក់ឱ្យអនុវត្តអនុក្រឹត្យ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*



TPPL